# ការសម្ភាសរបស់អ៊ុំស្រី អ៊ូរ យឿប

**កៈ អ្នកសម្ភាសឈ្មោះ លន់ មុណាក់**  **ខៈ អ្នកដែលត្រូវគេសម្ភាសឈ្មោះ អ៊ូរ យឿប**

## ពត៌មានសង្ខេបរបស់អ៊ុំស្រីៈ អ៊ូរ យឿប

សព្វថ្ងៃនេះអ៊ុំរស់នៅប្រទេសកម្ពុជាហើយ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរដំបង ឃុំអូរដំបងពីរ ស្រុកសង្កែ ខេត្តបាត់ដំបង។ ហើយអ៊ុំស្រីបានរៀបអាពាហ៍ពិពាហ៍នៅអាយុ២២ឆ្នាំ។ ហើយនៅក្នុងគ្រួសាររបស់អ៊ុំស្រី អ៊ុំស្រីមានបងប្អូនបីនាក់ហើយអ៊ុំស្រីជាកូនទីពីរ។ ហើយសព្វថ្ងៃនេះអ៊ុំស្រីមានអាយុ៥៧ឆ្នាំហើយអ៊ុំស្រីបានកើតនៅឆ្នាំ ១៩៥៥។ ហើយ សព្វថ្ងៃនេះអ៊ុំស្រីរស់នៅជាមួយនឹងកូនចៅប្តីរបស់អ៊ុំស្រីបានស្លាប់នៅជំនាន់សម្ចយប៉ុលពតដោយគេយកទៅសម្លាប់។

កៈ អញ្ចឹងជាំដំបូងខ្ញុំសូមជំរាបសួរអ៊ុំ!

ខៈ ចាស!

កៈ ចាស! អញ្ចឹងខ្ញុំមកពីខាងសាលាប៊ីវាយយូប្រ្សរ៉ូយូថាស៍នៅសហរដ្ឋអាមេរិចគេបានបានអញ្ជើញខ្ញុំមកថ្ងៃនេះដើម្បីធ្វើការសម្ភាសប្រជាជន់ខ្មែររបស់យើងហាស់អ៊ុំពីប្រវត្តិនឹងខ្សែជីវិតរបស់អ៊ុំតើអ៊ុំបានឆ្លងកាត់អ្វីខ្លះនៅក្នុងជីវិតរបស់អ៊ុំពីក្មេងហើយរហូតមកដល់ឥឡូវនេះ។ ហើយនិងពីខ្សែជីវិតរបស់អ៊ុំពីនៅជំនាន់សម័យប៉ុលពតចឹងហាអ៊ុំ។ អញ្ចឹងតើខ្ញុំអាចធ្វើការសម្ភាសអ៊ុំតើបានទេ?

ខៈ ចាសបាន!

កៈ ចាសអរគុណច្រើនអ៊ុំ! អញ្ចឹងខ្ញូមអ្នកសម្ភាសថ្ងៃនេះខ្ញុំឈ្មោះលន់មុណាក់។ ហើយថ្ងៃនេះជាថ្ងៃទី ២៩ ខែ ០៥ ឆ្នាំ ២០២០។

ខៈ ចាស!

កៈ អញ្ចឹងតើអ៊ុំស្រីមានឈ្មោះអ្វីដែល?

ខ៖ ខ្ញុំឈ្មោះ អ៊ូរ យឿប។

ក៖ អ៊ូរ យឿប?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើឆ្នាំនេះតើអ៊ុំស្រីមានអាយុប៉ុន្មានហើយ?

ខ៖ ៧៥ឆ្នាំ!

ក៖ អូ ៧៥ឆ្នាំ។

ខ៖ ៧៥!

ក៖ ចាស! អញ្ចឹងតើអ៊ុំមានចាំថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំដែលទេ?

ខ៖ ថ្ងៃខែឆ្នាំកំណើត: ឆ្នាំចរខែផល្គុន ថ្ងៃស្រុក។ មោនដឹងថា១០រោចឬក៏០៥រោចទេ?។

ក៖ ប់ឆ្នាំប្រហែលជាឆ្នាំប៉ុន្មានដែលអ៊ុំ? ១៩៥០ប៉ុន្មានឬក៏៧០ប៉ុន្មាន? ច្រឡំ៥០ប៉ុន្មាន, ប្រហែលជា៦០ឬក៏៧០ប៉ុន្មានដែលអ៊ុំ?

ខ៖ ឆ្នាំសព្វថ្ងៃនេះហ្ស?

ក៖ ចាស!

ខ៖ ឆ្នាំ ៧៥។

ក៖ ឆ្នាំ ៧៥ហ្សអ៊ុំ?

ខ៖ ចាស!

ក៖ ឆ្នាំ ១៩៧៥?

ខ៖ អត់ទេ! ដែលឆ្នាំអ៊ុំកើតហី?

ក៖ ចាសអ៊ុំ!

ខ៖ ដែលឆ្នាំអ៊ុំកើតឆ្នាំ១៩៤៥។

ក៖ អូ ៤៥ ហាហា។

ខ៖ ៤៥ យូរហើយ។

ក៖ ចាស យូរហើយ។

ខ៖ នឹងហើយ។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានចាំពីទីកន្លែងដែលអ៊ុំកើតទេ?

ខ៖ អ៊ុំកើតនៅកន្លែងនេះនឹង។

ក៖ នៅអូរដំបងពីរហ្មអ៊ុំ?

ខ៖ ចាសនឹងហើយ។

ក៖ ចាស! អញ្ចឹងក្រៅពីភាសាខ្មែរតើអ៊ុំមានចេះភាសាអ្វីផ្សេងក្រៅពីភាសាខ្មែរដែលឬទេអ៊ុំ?

ខ៖ អត់ទេ! អ៊ុំបានរៀនត្រឹមតែថ្នាក់ទីប្រាំបីទីប្រាំពីរហ្ម! អត់ចេះទេ។

ក៖ អូចាស! សម័យនឹងអ៊ុំ។

ខ៖ ចាសនឹងហើយ។

ក៖ អញ្ចឹងតើអ៊ុំចេះសរសេរហើយនឹងចេះអានបានល្អតើហីអ៊ុំ? អក្សរខ្មែររបស់យើង

ខ៖ ចេះ! ចេះសរសេរហើយនឹងចេះមើល។

ក៖ ចាស! អញ្ចឹងកាលដែលអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំប្រុសហាស់តើអ៊ុំមានចាំថ្ងៃណាខែណាឆ្នាំណាទេអ៊ុំ?

ខ៖ ហាកសួរអញ្ចឹងទៀត? ពិបាកទៀតហើយ! មិនចាំទេ។

ក៖ អត់ចាំថ្ងៃទេណ៎អ៊ុំ?

ខ៖ ចាសនឹងហើយ! យូរហើយមិនចាំថ្ងៃទេ។

ក៖ អត់អីទេអ៊ុំ! អត់ចាំក៏អត់អីដែល។

ខ៖ គ្រាន់តែដឹងថាពេលដែលរៀបការខ្លួនឯងអាយុ២២ឆ្នាំ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយប្តីខ្ញុំគាត់២៧។

ក៖ ចាសអ៊ុំ!

ខ៖ ហើយដឹងតែប៉ុន្នឹងឯង។

ក៖ ចាសអ៊ុំ!

ខ៖ ចាសនឹងហើយ!

ក៖ ចាសអត់អីទេ! ចាំខ្ញុំយកទៅដកឆ្នាំ២០២០ទៅនឹងដឹងថាអ៊ុំបានរៀបការនៅឆ្នាំណា។

ខ៖ ចាសនឹងហើយ!

ក៖ ចាសអញ្ចឹងតើការរៀបការរបស់អ៊ុំតើបានរៀបចំឡើងដោយឪពុកម្តាយឬក៏អ្នកណាដែល?

ខ៖ រៀបចំឡើងដោយឪពុកម្តាយ។ ហើយនៅនឹងផ្ទះនឹង។ ហើយផ្ទះរើរបាត់ហើយ។

ក៖ ផ្ទះរើរបាត់ហើយ?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំពីពេលដែលអ៊ុំហើយនឹងអ៊ុំប្រុសបានជួបគ្នាជាមួយអ៊ុំប្រុសហាស់ពីប្រវត្តិសេហ្នារបស់អ៊ុំខ្លះៗតើអ៊ុំបានដែលទេតើអ៊ុំមានចាំទេ?

ខ៖ អែ! ថាចាំក៏ដូចជាមិនចាំដែល។ អត់មានបានទៅជួបគ្នានៅកន្លែងណាផង។ គ្រាន់តែចូលផ្ទះអ៊ុំនីប៉ុនណឹងហើយក៏គេចូលស្តីដណ្តឹងទៅ។ ចាសនឹងហើយ! ទៅលេងផ្ទះបងនៅវត្តសំពៅដល់ពេលគេមកនឹងទទៅក៏ឃើញ។

កៈ ចាសអ៊ុំ!

ខៈ អត់មានបានដើរទៅណាមកណាអីទេអត់ទេ។ ពីដើមមិនមែនមានកង់ជិះដូបយើងឥឡូវនេះទេ។

កៈ ចាសអ៊ុំ!

ខៈ ចាស! តាមម៉ែឪ។

កៈ ចាស! អញ្ចឹងជួបគ្នាបានម្តងណឹង...? រៀបការប៉ុនដោយ?

ខៈ ចាស! ហើយឪពុកម្តាយរបស់គេក៏មកចូលស្តីដណ្តឹងទៅ។

កៈ ចាសអ៊ុំ! អូខេនឹង។ អញ្ចឹងនៅក្នុងគ្រុនគ្រួសាររបស់អ៊ុំតើអ៊ុំមានបងប្អូនប៉ុន្មានអ្នកដែល?

ខៈ មានបងប្អូនបីនាក់។

កៈ ចាស!

ខៈ បីនាក់! ខ្ញុំនេះហើយទីពីរ។ ប្តីអ៊ុំម៉ៅស្គាល់អ៊ុំម៉ៅដែល? ម៉ៅមុំ។

កៈ ចាស! អញ្ចឹអ៊ុំស្រីជាកូនទីពីរនេះ?

ខៈ ចាស! ហើយនឹងអ៊ុំយ៉ុន។

កៈ ចាស! អញ្ចឹងតើបងប្អូនរបស់អ៊ុំពីរនាក់ទៀតតើពួកគាត់រស់នៅស្រុកខ្មែរទាំងអស់តើហីអ៊ុំ?

ខៈ នៅ! នៅស្រុកខ្មែរតែកណ្តាលគេនឹងគេយទៅបាត់ហើយ(ស្លាប់) នៅតែអ៊ុំយ៉ុនទេ។

កៈ ចាសអ៊ុំ!

ខៈ កណ្តាលគេយកទៅបាត់ហើយ។

កៈ ចាស!

ខៈ គេសម្លាប់នៅសម័យប៉ុលពត។

កៈ អូ! គេសម្លាប់គាត់ហី?

ខៈ ចាសនឹងហើយ។

កៈ ចាស! អ៊ុំនិយាយាថាគេយកអញ្ចឹងខ្ញុំអត់ដឹងថាគេយកគាត់ទៅណា។ ហាហា

ខៈ ចាសគេយកទៅសម្លាប់ចោល។

កៈ ចាសអ៊ុំ! អញ្ចឹងកាលដែលគេយកប្អូនរបស់អ៊ុំទៅសម្លាប់ចោលនឹងតើគាត់មានអាយុប៉ុន្មានឆ្នាំហើយ? តើអ៊ុំមានចាំដែលឬទេ?

ខៈ ប្អូនខ្ញុំកាលនឹង! កាលនឹងយួនចូលទឹមតែចូលបានពីរបីឆ្នាំ..បីឆ្នាំ! មើលអាយុវាប៉ុន្មានទេ។

កៈ ២០ ជាងហីអ៊ុំ?

ខៈ ចាសនឹងហើយ! ប្អូនអ៊ុំបីឆ្នាំ។

កៈ ចាស! អញ្ចឹងតើកាលនឹងតើគាត់បានធ្វើអ្វីខុសបានជាគេយកគាត់ទៅសម្លាប់ចោលចឹងអ៊ុំ?

ខៈ កាលនឹងមិនមានអ្វីខុសទេ។ កាលនឹងពួកអ្នកស្រុកយើងនឹងអ្នកជិតខាងយើងនឹងវាស្អប់គ្នាហើយចេះតែថាចេះថាចុះទៅ។ មានអីកាលនឹងបើកឡាននឹងអត់មានធ្វើអីផងនឹង។

កៈ ចាសអ៊ុំ!

ខៈ បើកឡានដឹកអំបិលដឹងអង្ករអីនឹងទៅភ្នំពេញទៅកំពង់សោមអីអញ្ចឹងហាស់។តែប៉ុនណឹងហើយអត់មានធ្វើអីផង។

កៈ ចាសអ៊ុំ! អញ្ចឹងកាលសម័យនឹងគេចាត់អោយធ្វើការខាងនឹងហីអ៊ុំ?

ខៈ ចាសខាងនឹង!នឹងសម័យប៉ុលពតទេណា?។

កៈ ចាសអ៊ុំ!

ខៈ អូ! អត់ទៃសុម័យសង្គមទេណា! ដល់តែពេលចូលប៉ុលពតទៅគេមូលបង្កាត់យើងថាស្អីៗយើងវាមិនដឹង។

កៈ ចាសអ៊ុំ!

ខៈ ស្រាប់តែគេចាប់គាត់យកទៅអញ្ចឹងទៅណាស់។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ!

កៈ ចាស! អញ្ចឹងនៅក្នុងគ្រុមគ្រួសាររបស់, ក្នុងគ្រុមគ្រួសាររបស់អ៊ុំអ្នកដែលត្រូវបានប៉ុលពតខ្មែរក្រហមសម្លាប់នឹងតើមានច្រើនដែលឬអត់អ៊ុំ?

ខៈ អូ! មានតាយឿតមួយ។ អូ..យឿបមួយហើយហើយឪអាវគ្គមួយ។ មានពីរនាក់។

កៈ ចាស! ពីរនាក់ហ្ស៎អ៊ុំ?

ខៈ ចាសពីរនាក់។

កៈ អញ្ចឹងតើពីរនាក់គាត់នឹងតើពួកគាត់បានធ្វើអ្វីខុសពីគោលការណ៍របស់កាលណឹងឬក៏យ៉ាងម៉េចដែល?

ខៈ មិនខុសអ្វីទេដូចដែលអ៊ុំបាននិយាយអញ្ចឹង! មានតែគ្នាឯងនឹងឯងដែលចាក់ចុកគ្នាហើយនិយាយចេះនិយាយចុះទៅវាទៅជាខុសទៅ។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ!

កៈ អូ! ទាំងពីរម៉ងណ៎អ៊ុំ?

ខៈ ចាសនឹងហើយ! អត់មានបានធ្វើស្អីផង។ ហើយម្នាក់ធ្វើស្រែចំការហើយម្នាក់ទៀតបើកឡាន។

កៈ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំមានចាំ! អញ្ចឹងតើឪពុកម្តាយរបស់អ៊ុំតើពួកគាត់មានឈ្មោះអ្វីដែលអ៊ុំ? ហើយចា...

ខៈ មានឈ្មោះនែ..ឪពុកខ្ញុំឈ្មោះ...ដូចចង់ភ្លេច។ ឈ្មោះប៊ិច។

កៈ ឈ្មោះប៉ិច?

ខៈ ចាសនឹងហើយ! ហើយនាមត្រកូលគាត់ឈ្មោះ អ៊ួរដែល។ ហើយនឹងនាមរបស់ឪពុកគាត់ហាស់?

កៈ ចាសអ៊ុំ!

ខៈ ម៉ែឈ្មោះអឿន, ចាន់ អឿន។

កៈ ចាសអ៊ុះ! ចុះអ៊ុំតើមានចាំពីជីដូនជូតារបស់អ៊ុំដែលឬទេតើពួកគាត់មានឈ្មោះអ្វី?

ខៈ ជីដូនជីតាក៏ចាំដែល។ តាខាងឪបុកនោះមានឈ្មោះ តាអ៊ួរ យាយចិន។ ហើយខាងម្តាយឯនេះ តាចាន់យាយអ៊ុច។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ។

កៈ ចាសអញ្ចឹងតើអ៊ុំមានចាំពីទីកន្លែងកំណើតរបស់ពួកគាត់ដែលឬទេអ៊ុំ?

ខៈ កំណើតរបស់គាត់? យាយតានឹងហី?

កៈ ចាសអ៊ុំ!

ខៈ នឹងហើយនៅត្រើយខាងនេះ។

កៈ នៅបាត់ដំបង? ហើយអូរដំបង?

ខៈ នៅនឹងអូរដំបងនេះដែល។

កៈ ចាស!

ខៈ ចាស!ហើយបើយាយតាខាងឪពុកពួកគាត់នៅខាងអន្លង់វិល។

កៈ អូ! ចាសអ៊ុំ!

ខៈ នៅអន្លង់វិល។

កៈ ចាស! ហើយម្តាយរបស់អ៊ុំគាត់នៅនឹងអូរដំបងនេះដែល?

ខៈ ចាស! អូរដំបងនេះដែល។

កៈ ចាសដូចគ្នាទាំងអស់អញ្ចឹង។ចាសអញ្ចឹងតើឪពុកម្តាយរបស់អ៊ុំតើពួកគាត់ស្លាប់អស់ហើយឬនៅ?

ខៈ សព្វថ្ងៃនេះហ្ស?

កៈ ចាស!

ខៈ គាត់ស្លាប់តាំងពីប៉ុលពតឪពុក។

កៈ ចាស!

ខៈ ហើយដល់ពេលចូលមកនឹង នៅម្តាយបានស្លាប់។

កៈ គាត់តទឹមតែស្លាប់ឥឡូវនេះដែលឬក៏ម៉ែចអ៊ុំ?

ខៈ ទេយូរដែលហើយ។ យូរហើយ!

កៈ ចាស!

ខៈ មីអូនទឹមតែកើតបានគិតទៅបាន៣០ឆ្នាំជាងហើយ។

កៈ ចាស!

ខៈ វាកើកតបានពីរខែបានគាត់ខូច។

កៈ ចាស!

ខៈ នឹងហើយ។

កៈ ហ៊ឹម! អញ្ចឹងតើអ៊ុំបានចាំដូចជាអ្វីខ្លះពីឪពុកម្តាយរបស់អ៊ុំហាស់តើកាត់បានបង្រៀនហើយបានប្រាប់អ្វីគេដល់អ៊ុំខ្លះ?

ខ៖ អូ! គាត់បានបង្រៀនអក្សរចេះស្រៈចេះបំបែក។ ដូចថាគាត់មកសរសេរអោយតិចទៅហើយគាត់ទៅធ្វើស្មៅអញ្ចឹងទៅ! ហើយគាត់សួរសេរសេរចប់ហើយឬនៅ? ចាំហើយឬនៅ? ហើយមកប្រាប់ទៀតទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ខ្ញុំចាំមើលអក្សរដាច់បានបានខ្ញុំចូលរៀនហាស់។ ជាំប្អូនអាយុប្រាំពីរឆ្នាំ ហើយខ្ញុំអាយុដប់ឆ្នាំបានបានចូលរៀន។

ក៖ ចាសអ៊ុំ!

ខ៖ បងប្អូនពីរនាក់។ ហើយអាប្អូននោះវាកើតក្រោយទៅ, ប្អូនក្រោយ យ៉ុង។

ក៖ ចាសអ៊ុំ!

ខ៖ ហើយខ្ញុំបងច្រើនណាស់។

ក៖ ចាស! អញ្ចឹងម្ដាយរបស់អ៊ុំបានបង្រៀនអ៊ុំអោយចេះអានហើយនឹងចេះសរសេរអក្សរ?

ខ៖ ចាសនឹងហើយ! ចេះអានហើយនឹងចេះសរសេរ។

ក៖ ចាសអញ្ចឹងអ៊ុំរៀនជាមួយម្ដាយរបស់អ៊ុំចេះសិនបានអ៊ុំទៅសាលារៀន?

ខ៖ ចាសបានគាត់យកទៅដាក់នៅសាលារៀន។ នាំចូលរៀន។

ក៖ អូ! ម៉េចបានអត់ចូលរៀនមុននឹងអញ្ចឹងអ៊ុំ?

ខ៖ ចាំប្អូន! ប្អូនវាអាយុតិចហើយចាំអោយប្អូនបានអាយុប្រាំពីរឆ្នាំសិន។

ក៖ អូ!

ខ៖ ខ្ញុំបងវាបៅឆ្នាំ។

ក៖ ចាសអ៊ុំ!

ខ៖ ឆ្នាំចរហើយនឹងឆ្នាំឆ្លូវ។

កៈ ចាសនឹងហើយអ៊ុំ!

ខៈ ចាស!

កៈ ចាស! អញ្ចឹងតើអ៊ុំមានបងប្អូនណាដែលពួកគាត់រស់នៅក្រៅប្រទេសដែលឬទេ?

ខៈ អត់មានទេ! អត់មានទេ។

កៈ នៅកម្ពុជាយើងទាំងអស់ស្រុកខ្មែរយើងទាំងអស់ន៏អ៊ុំ?

ខៈ ចាសនៅស្រុកខ្មែរទាំងអស់។

កៈ ចាសអញ្ចឹងតើអ៊ុំបានធ្លាប់បានទៅណាឆ្លងខេត្តឬក៏ឆ្លងប្រទៃសអីដែលឬទេអ៊ុំ?

ខៈ អត់ទេ។ អត់មានទេទភត្រឹមទេភ្នំពេញអីនឹងឯង។

កៈ ទៅថៃទៅអី?

ខៈ អត់ទេ!

កៈ អញ្ចឹងទៅបានត្រឹមតែភ្នំពេញទែន៏អ៊ុំ?

ខៈ ចាស! នឹងហើយទទៅត្រឹមតែភ្នំពេញ។

កៈ ចាសនឹង! អញ្ចឹងតើអ៊ុំអាចប្រាប់ពីជីវិតរបស់អ៊ុំបានទេតើអ៊ុំបានធំឡើងយ៉ាងដូចម៉េចដែល?

ខៈ ទេកាលដែលរសើនៅជានៅជមួយម្ដាយអី?

កៈ ចាសចាស!

ខៈ នឹងហើយ! មានអីនៅជាមួយម្ដាយទៅរៀនទៅអីទៅ។ មកវិញទៅហើយញាំបាយញាំអីហើយិតចទៅរៀនទៅអីវិញទៅ។ ហើយមុនដំបូងទៅរៀននៅសាលាវត្តចាដឹក។ ចង់ពីវត្តចាដឹកទៅ, មុនដំបងបូងគេនៅវត្តចាដឹកហើយវត្តតាម៉ិមហើយមកទៀតបានវត្តកំផែង។

កៈ ចាសអ៊ុំ!

ខៈ ហើយទៅវត្តាំផែងដើរហាស់! កាត់តាមថ្នល់រទេះភ្លើងទៅហាស់កាលនឹង។

កៈ ចាសអ៊ុំ!

ខៈ ចាស!

កៈ ហ៊ឺ!

ខៈ កាត់តាមថ្នល់រទេះភ្លើងទៅ។ កាត់ទៅទៅដល់ស្ពាននេកវត្តសំពៅហើយហួសវត្តសំពៅតិច គេហៅវត្តកំផែងហី?

កៈ ចាសអ៊ុំនឹងហើយ!

ខៈ នឹងហើយ! ថ្ងៃឡើងជូនណាទៅយប់ល្ងាចក៏ក្រោកមកផ្ទះមក, ហើយជូនណាទៅក៏ក្រោកពីយប់ទៅទៅ។ ចាស!ដល់ទៅនឹងម៉ែគាត់ពិបាកពេកក៏នៅជាមួយបងនីដែលគាត់នៅតានេះកូនអ៊ុំអ្ហួមហាស់?

កៈ ចាសអ៊ុំ!

ខៈ ក្រោកពីយប់ឡើង! ម្តាយគាត់ដាំបាយអោយខ្ចប់ទៅឪពុកគាត់ទៅអោយដល់វត្តសំពៅនឹងហាស់។

កៈ ចាសអ៊ុំ!

ខៈ ពីរកញ្ចាប់បងប្អូនពីនាក់ទៅនៅនឹងកលនឹង។

កៈ ចាស!

ខៈ ចាសមួយកញ្ចប់ម្នាក់! ទៅហើយគាត់ដាំស្លរខ្លួនគាត់ទៅ, ហើយមកដាក់ញាំជាមួយទៅគោកៗអោយរាល់តែថ្ងៃនឹងឯង។

កៈ ចាសអ៊ុំ!

ខៈ ចាសចុះទៅអញ្ចឹងមានបានស្លរអី។

កៈ ចាសអ៊ុំ!

ខៈ បានត្រីងៀតហើយពងទាអីតែប៉ុននឹង។

កៈ ចាស!

ខៈ ចាស!ម៉ែគាត់គិតណាស់គាត់គិតពីកូនចៅណាស់។

កៈ ចាសអ៊ុំ!

ខៈ ហើយទៅរៀនអីអោយជូនទៅហើយ។

កៈ ចាស!

ខៈ ដឹងថាទៅនោះឆ្ងាយ។

កៈ ចាសអ៊ុំ!

ខៈ ហើយនៅនេះគ្មានសាលារៀនទេណាស់គេទើមទែបង្កើតទេណាស់។ ពីដើមគ្មានសាលារៀនទេពីដើមគេទឹមតែបង្កើតទៃណាស់សាលាវត្តតាមិម។

កៈ ចាសអ៊ុំ!

ខៈ ចាស! ហើយនិងនៅវត្តកំផែង។

កៈ ចាស! អញ្ចឹងពីមុននឹងអ៊ុំ, អ៊ុំដើរពីផ្ទះនេះទៅរៀនដល់វត្តកំផែង?

ខៈ ចាស! ទៅរៀនដល់វត្តកំផែង។

កៈ វត្តកំផែង។

ខៈ ចាសប៉ុន្តែទៅជ្រកកោននៅនឹងផ្ទះអ៊ុំ។

កៈ ចាស!

ខៈ ផ្ទះអ៊ុំ ផ្ទះបងនឹងនៅនឹងវត្តសំពៅ។

កៈ នៅវត្តសំពៅ?

កៈ ចាស! អូ!

ខ៖ ឆ្ងាយណាស់!

ក៖ ចាសឆ្ងាយ។

ខ៖ ឆ្ងាយ!

ក៖ អញ្ចឹងតើអ៊ុំដើបទៅរៀនតាំងពីម៉ោងប៉ុន្មានទៅបានបានដើរទៅដល់សាលាដោយសារតែវាឆ្ងាយដែលពីសាលា?

ខ៖ នេក! អញ្ចឹងខ្ញុំនៅសំរាកនៅឯនោះហើយព្រលឹមឡើងបានម្ដាយយកបាយទៅអោយ។

ក៖ ចាស!

ខ៖ ចាសនៅវត្តសំពៅនឹង។

ក៖ ចាស!

ខ៖ ចាស! ឆ្លងថ្នល់រទេះភ្លើងទៅ! ហើយពេលទឹកជន់ទឹកអីលិចខ្លាចមិនហ៊ានអោយមក។ ចុះគាត់មិនហ៊ានអោយឆ្លងហ្វ!?

ក៖ ចាសអ៊ុំ!

ខ៖ ឆ្លងស្ទឹងនឹងឯង។

ក៖ ចាសអ៊ុំ!

ខ៖ អញ្ចឹងឯង។

ក៖ អញ្ចឹងកាលដែលអ៊ុំទៅរៀននឹងតើអ៊ុំបានរៀនដល់ថ្នាក់ទីប៉ុន្មានដែល?

ខ៖ រៀនបានដល់ថ្នាក់ទៅប្រាំបីដែល។ ដល់ពេលគេអោយរៀនភាសាបារាំរៀនមិនចេះមែនណាស់។ ហាហា! ដូចគោពាក់ឡាំងមែនណាស់មោនចេះហើយសុំម៉ែឈប់ប៉ុនដោយទៅ។ ហើយមានប្អូនសុំម៉ែមើលប្អូន( ប្អូនយ៉ុង )។

ក៖ ចាសអ៊ុំ!

ខ៖ ចាសនឹងហើយ!

ក៖ អូ! អញ្ចឹងនៅជំនាន់នឹងគែមានភាសាបារាំហើយនឹងភាសាអង្គគ្លេសរៀនហើយន៍អ៊ុំ?

ខ៖ ចាសមានហើយ! គេចាប់ផ្ដើមបង្រៀនហើយពីថ្នាក់ទីប្រាំពីរទីប្រាំបីហ្ន។

ក៖ អូចាស!

ខ៖ ទីប្រាំពីរទៅប្រាំបីហ្ន។

ក៖ អូឡូយមែនទែន។ ខ្ញុំស្មានតែទឹមតែមានសម័យដូចថាប៉ុន្មានឆ្នាំនេះដែល។ តេតាមពិតទៅមានមកយូរហើយ។

ខ៖ ចូលមកនេះហាស់? មាន! អ្ហឹកាលនឹង អ្នកប្រឡងជាប់ត្រឹមតែឌីប្លូមគែប្រឡងចូលធ្វើគ្រូបង្រៀនបានហើយគែចេះនោះ។

ក៖ គ្រូបង្រៀនភាសាបារាំហ្នអ៊ុំ?

ខ៖ អត់ទេធ្វើគ្រូបង្រៀនហាស់!?

ក៖ អូ! ធ្វើគ្រូបង្រៀនភាសាខ្មែរយើងហ្ន?

ខ៖ ចាស! បង្រៀន។ រៀនឌីប្លូមចប់នឹង។ ចបទៅរៀននៅកំពង់ក្រទូតហើយធ្វើគ្រូបាត់ហើយ។

ក៖ ចាស!

ខ៖ សព្វថ្ងៃនេះអត់ទេ! រៀនចប់បាក់ឌុបហើយមិនបានធ្វើគញ្ញូរទៀត។

ក៖ ចាស! មិនងាយចូលទេសម័យឥឡូវ។

ខ៖ ចាស! សម្បូរមនុស្សណាស់សម័យឥឡូវពីដើមវាក្រ។ គ្រូចង់ចាស់ៗអស់ហើយ។

ក៖ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំបានទៅរៀននៅសាលាណាខ្លះឬក៏អ៊ុំបានទៅរៀនតែមួយសាលាទេ?

ខ៖ រៀន! ទៅរៀនបានពីរឆ្នាំ។

ក៖ ចាស!

ខ៖ បានពីរឆ្នាំពីរថ្នាក់ដែល។ បានទីប្រាំពីរហើយនឹងទីប្រាំបី។ ហើយឈប់បានទីប្រាំបីបានតែពាក់កណ្តាលនឹងឯង។

ក៖ អូចុះទីមួយទីពីរ?

ខ៖ យើងពីដើមគេហៅទីមួយទីពីរ។

ក៖ អូគេរ៉ាប់ចុះក្រោមវិញន៍អ៊ុំ?

ខ៖ អើចាសទីមួយទៅពីរ!

ក៖ ចាស!

ខ៖ ឥឡូវ! បញ្រ្ចាស់មកវិញ។

ក៖ ចាស! ទីប្រាំពីរទីប្រាំបី!

ខ៖ ចាស!

ក៖ ស្មើរនឹងទីមួយទីពីរ។

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងសាលាដែលអ៊ុំរៀននឹងតើអ៊ុំមានចាំទេថាឈ្មោះអ្វី?

ខ៖ សាលាគេហៅថាសាលាវត្តកំផែងចឹងម៉ង។

ក៖ គែហៅវត្តកំផែងចឹងម៉ង?

ខ៖ ចាស!

ក៖ នឹងហើយ! អញ្ចឹងតើអ៊ុំទៅរៀននឹងតើអ៊ុំមានលុយដម្បីទកភរៀនដែលឬទេ?

ខ៖ ចាសលុយកាលនឹងលុយនៅថ្លៃហាស់?

ក៖ ចាសអ៊ុំ!

ខ៖ គាត់អោយទៅមួយថ្ងៃបីរយ។

ក៖ បីរយរៀលយើងនឹងមែនអ៊ុំ?

ខ៖ ចាសបីរយរៀនយើងនឹងខ្មែរយើងនឹង។

ក៖ អូ! កាលនឹងច្រើន។

ខ៖ ចាសច្រើន! ហើយកាលនឹងគុយទាវមួយចានតែបីរយ។

ក៖ ចាសអ៊ុំ!

ខ៖ បីរយ! បីរយ, ហើយទៅរៀនញ៉ាំតែមួយរយៗទៅវាគញរប៉ាបត់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ គុយទាវមួយចានបីរយ!

ខ៖ ចាសនឹងហើយ!ហើយចេកចៀនពីរមួយរយ។

ក៖ ចាសនឹងហើយអ៊ុំ! អញ្ចឹងបីរយអ៊ុំបានប្រាំមួយចេក?

ខ៖ ចាសនឹងហើយបានប្រាំមួយចេក។

ក៖ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំគិតថាលុយបីរយនឹងអ៊ុំញ៉ាំគ្រប់គ្រាន់ទេ? សម្រាប់ការទេភរៀននៅពេលនឹង?

ខ៖ អូ! ប៉ុននឹងថាគ្រប់ក៏ដូចវាមិនគ្រប់ដែល។ យើងមិនមែនជាអ្នកចាយធំដូចគេមានហាស់?។

ក៖ ចាសអ៊ុំ!

ខ៖ គេមាន! កូនគេអ្នកមានគេទៅរៀនឃើញតែគេចាយច្រើន។ យើងមានប៉ុនណាយើងចាយប៉ុននឹងទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ ចាសនឹងហើយអ៊ុំ!

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើអ៊ុំអាចរប្រាប់ពីខ្សែជីវិតរបស់អ៊ុំ, អ៊ុំធ្លាប់បានឆ្លងកាត់ពីសម័យប៉ុលពតមែនទេ?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំប្រាប់ខ្ញុំពីជីវតរបស់កាលនឹងបានទេ? តើគេអ៊ុំបានជួបនូវការលំបាកអ្វីខ្លះហើយតើកេបានប្រើអ៊ុំអោយធ្វើការអ្វីខ្លះអញ្ចឹងហាស់អ៊ុំ?

ខ៖ ចាសចា!

ក៖ ចាសអ៊ុំ! អញ្ចឹងខ្ញុំសូមអ៊ុំចែកចាយជាមួយខ្ញុំតិចតើបានទេ?

ខ៖ ចាស! កាលនឹងទៅនៅទៅ, ធ្វើផ្ទះតូចៗនៅហាស់?។

ក៖ ចាសអ៊ុំ!

ខ៖ នៅទៅដល់ពេលថ្ងៃឡើង, មិនមែនថ្ងៃទេ។ ព្រលឹនឡើងគេអោយទៅធ្វើការធ្វើអីនឹង។

ក៖ ចាសអ៊ុំ!

ខ៖ យកកំបិតចបអៅទៅ! ហើយដល់ពេលបាយក៏ចេញមកបាយមក។

ក៖ ចាស!

ខ៖ ហើយដល់ពេលម៉ោងល្ងាចទៅមាន,អ្នកមានកូនតូចអោយគេមើល។ មានអ្នកមើលអញ្ចឹងហាស់?!

ក៖ ចាសអ៊ុំ!

ខ៖ ជូនកាលក៏ទៅកិនស្រូវ! គេម្តងអោយធ្វើអានេះគេម្តអអោយធ្វើអានោះហាស់? មិនមែណម្តងនទៀងទាត់តែមួយមួយមុខទេ។

កៈ ចាសអ៊ុំ!

ខៈ ដល់ល្ងាចឡើងជូនណាក៏គេអោយទៅយាមទៅ។

កៈ ចាសអ៊ុំ!

ខៈ ចាស! ហាហា។ ដល់ពេលនេះទៅម្ដាយគែអោយទៅធ្វើការដែល។ ខ្វ។កុំអោយតែជាប់កូនទេណាស់!? កុំអីមិនបាននៅផ្ទះទេណាស់?

កៈ ចាសអ៊ុំ!

ខៈ ប៉ុន្តែអ្នកណាគ្មានកូនទៅសំប្រុកសត្វ! ទៅកន្លែងឆ្ងាយៗណាស់។

កៈ ចាសអ៊ុំ!

ខៈ ហើយទៅនៅនឹងម៉ង។ មិនមែនទៅវិលល្ងាចមកវិញដល់ទេ។

កៈ ចាសអ៊ុំ!

ខៈ សម័យនឹងហ្វ!

កៈ ចាស!

ខៈ ហើតកន្លះខែមួយខែអីបានមកជួបកូនធំៗម្ដង។

កៈ ចាសអ៊ុំ!

ខៈ កូនគេយកទៅដាក់នៅតាមផ្ទះទៅ! អត់បាននៅផ្ទះជាមួយទេ។

កៈ ចាសអ៊ុំ!

ខៈ ចាស! វាអញ្ចឹង។ យប់ឡើងគែអោយពរកូនទៅ, ទៅយាមណោ៎ម៉ាស៊ីនស្រូវម៉ាស៊ីនអីនឹងទៅ។

កៈ ចាសអ៊ុំ!

ខៈ គ្នាបីនាក់! ហើយថ្ងៃឡើងក៏ទៅយាមដែល។

កៈ ចាសអ៊ុំ!

ខៈ នឹងចំពោះតែអ្នកមានកូននៅបៅហាស់!?

កៈ ចាសអ៊ុំ!

ខៈ មាននៅបៅនៅជាប់អញ្ចឹងគេអត់យកកូនទៅមើលទេ។ តៅនៅយាមតាមខ្ទមតាមចំការអើទៅមានអ្នកណាមកចំឡែងអីយើងសួរនាំតែទៅណាស់!?

កៈ ចាសអ៊ុំ!

ខៈ ហើយប្រាប់គែទៅ។ ចាសអ្នកច្រូតស្មៅច្រូតអីទៅជូនណាទៅវាដើរប្រលំអីចឹងទៅ។ តែប៉ុនណឹងរាល់ថ្ងៃ។

កៈ ចាសអ៊ុំ! អញ្ចឹងអ៊ុំគែបានប្រើអ៊ុំអោយធ្វើការងារច្រើនតើមែនទេ?

ខៈ ចាស!

កៈ តែខុសគ្នា?

ខៈ ចាសខុសគ្នា។

កៈ ចាស! អ៊ុំសម្រាប់អ៊ុំផ្ទាល់តើអ៊ុំគិតថាពេលនឹងអ៊ុំពិបាកដែលឬអត់ពិបាកកខ្លាំងអត់នៅក្នុងជីវិតរបស់អ៊ុំហាស់?

ខៈ ចាស!? ពិបាកពិបាក។ គិតអីមិនចេញទេ។ ហោកបើថាយើងនៅផ្ទះយើងគិតអីយើងទិញអី៖ ឧបមាថាហោកចង់អីយើងមានលុយទៅទិញមក, ហើយកាលនោះវាគ្មានលុយវាមិនមានគេលក់វាងត់។

កៈ ចាស!

ខៈ ហើយបើចង់អីបានត្រឹមតែឈ្លានទេ! តែវាអត់វាអត់មានអ្វីទាំងអស់។

កៈ ចាសអ៊ុំ!

ខៈ នៅប៉ុន្មានឆ្នាំនឹងមិនដែលថាបានខ្នុលបានដូងអីញ៉ាំទេ។

កៈ ចាស!

ខៈ ទោះបីជាមានក៏គេប៉ះ, ពួកនៅអង្គការនឹងគែប៉ះយកខ្លួនគេហាស់!?

កៈ ចាសអ៊ុំ!

ខៈ មិនដឹងថាគេដឹកទៅឯណាអីឯណាទេ។

កៈ ចាសអ៊ុំ!

ខៈ កិនស្រូវក៏អញ្ចឹងដែលរហូតដល់ញាំបបរហាស់។ មានបានញាំបាយអី។

កៈ ចាសអ៊ុំ!

ខៈ បីកំប៉ុងមួយខ្វះហាស់? កក្កូរមកសុទ្ធតែទឹកទៅ។

កៈ ចាស!

ខៈ ចាស! ហើយចាក់ទឹលហុតអស់ទៅហើយកាកនឹងទុកអោយកូនទៅ! និងកូននៅតូចៗអាយុបីបួនឆ្នាំអីនឹងហាស់?។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ! ហើយអត់ឆ្អែតទេ។ ទៅអញ្ចឹងទៅទៅរកស្លឹកផ្លីស្លឹកអីយកមកហាន់ដាក់ចាន, ដាក់កន្លះចានហើយគែដួសបបរមកលាយ! លាយជាមួយនឹងបន្លែនឹងហូបទៅ មួយគ្រប់ៗនឹងហូ។

កៈ ចាសអ៊ុំ!

ខៈ នឹកឃើញ! នៅនឹកឃើញដល់សព្វថ្ងៃអត់ភ្លេច។ មិនភ្លេចទេរឿងនៅសម័យប៉ុលពតហូ។

កៈ ចាសអ៊ុំ!

ខៈ ចាស!

កៈ ចាសនឹងហើយអ៊ុំ! តើអ៊ុំមានទៀតដែលឬអត់? តើអ៊ុំមានចងចាំអីទៀតដែលឬអត់ពីសម័យនឹងហាស់?

ខៈ អូ! ចងចាំដូចប្តីគេយកទៅសម្លាប់គែយកទៅសម្លាប់អីនឹងក៏ដឹងដែល។

កៈ ចាសអ៊ុំ! អញ្ចឹងសូមអ៊ុំនិយាយអោយអស់មក!

ខៈ ចាស! ចាសនៅឯទួលសំបុត្រសត្វងនោះ។ គេដឹកមកនៅនឹងកន្លែងការដ្ឋានវ៉ាយសព្វថ្ងៃនេកក្រៀនផ្ទះនេក។ ផ្ទះខ្មោចបងរ៉េតផ្ទះតាដន។ គេយកមកគេដឹកយកមក។ ខ្ញុំដើររទៅជួបនឹងពេលដែលខ្ញុំកិនស្រូវ។ ពេលចេញមកបាយ, ហើយអង្គុយនីលើរទេះមុខឡើងស្ងួត។ ហើយខ្ញើក៏សួរតើគែអោយទៅណា?

កៈ ចាស!

ខៈ ខ្ញុំមិនដឹកថាគែអោយទៅណាទេ! គេកំពុងតែអោយទៅ! ហើយដល់ពេលដែលសួរៗគេប្រាប់អោយទៅភូមិមកភូមិ។ ហើយក៏អង្គុយនៅនឹងទៅ។ ហើយនិយាយាពីរឿងដំណឹង។

កៈ ចាសអ៊ុំ!

ខៈ តាណឹងខ្ញុំចាំរហូតណាស់។

កៈ ចាសអ៊ុំ!

ខៈ កាលណឹងគែចែកបាយមក, គែអោយតែមួយរបបហើយខ្ញុំដឹង! ខ្ញុំដឹងថាប្តីរបស់ខ្ញុំគាត់អត់បាយតាំងតែពីន៉មកហ្វ?

កៈ ចាសអ៊ុំ!

ខៈ អត់តាំងពីនោះមកចុះមកពីនោះមកគែមានអោយអងង្ករអោយអីចែក។

កៈ ចាស!

ខៈ ហើយប្រើកូនយកបាយទៅអោយ។ អាកូនដែលល្លង់ទឹកនឹងហាស់?

កៈ ចាសអ៊ុំ!

ខ៖ ដែលងាប់នឹង! យកបាយទៅអោយទៅ! ហើយអង្ករគេអោយមកហើយ គេអោយមកបីកំប៉ុង។

ក៖ ចាសអ៊ុំ!

ខ៖  ជូនប្អូនថ្លៃ,ជូនប្អូនថ្លៃទៅដាំបាយ! អ៊ុំម៉ៅនៃក។

ក៖ ចាសអ៊ុំ!

ខ៖ អោយមក! គែមិនដាំអោយទេ។ គេយកទៅទុកគែមិនដាំអោយទេគេយកទៅគែទុកគែមិនដាំទេ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយខ្ញុំថា! បើសិនជាំគែអោយបាយនឹងចាំយកមកញាំខ្លួនឯង។ ហើយចាំយករបបខ្លួនឯងអោយកូនយកទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយកូនយកទៅអោយទៅបានបាយនឹងឯង។ ហើយចុះបាយពីដើមមិនបានមួយកំប៉ុងផង។

ក៖ ចាស!

ខ៖ ចាសនឹងហើយ! តិចៗនឹង។

ក៖  មួយចានយកទៅអោយទៅ។ ហើយប្រើកូនអោយទៅដួសទឹកនៅក្នុងអណ្តូងយកមកអោយ។ ខ្ញុំនៅតែចាំនៅតែផ្ទះនឹងទៅ។ ហើយដល់ពេលចាំយូរពេក, កាលនឹងបាយមិនមែនតែមួយរបបទេអាកូនខ្ញុំមួយនឹងផងហើយខ្ញុំមួយនឹងផងហើយអាខ្មោចកូនអ៊ុំញុំាអាំខ្មៅមួយទៀតហ្ង?

ក៖ ចាស!

ខ៖ បីរបបបហាស់យកទៅអោយហាស់!?

កៈ ចាសអ៊ុំ!

ខៈ អាងតែគេអោយអង្ករបីកំប៉ុងយកទៅអោយចុងភៅដាំ។

កៈ ចាសអ៊ុំ!

ខៈ តែចុងភៅមិនហ៊ានដាំអោយឯណា, វាហូតអង្ករយកបាត់ទៅវាមិនដាំអោយយើងណា។

កៈ ចាសចាស!

ខៈ ហើយក៏អត់ទៅ! អាក្មួយនោះក៏យំអីក៏យំ។ ហើយលួងថាចាំតិចទៀតយកបាយមកអោយហើយ។

កៈ ចាសអ៊ុំ!

ខៈ អត់! អត់មានយំទាល់តែវាដេកលក់។

កៈ ចាស!

ខៈ ហើយខ្លួនឯងនឹងក៏អត់។ ចុះយើងមានអង្ករឯណាយើងនៅផ្ទះហូគេដើរឆែតហាស់មិនបានទេ។

កៈ ចាសអ៊ុំ!

ខៈ ដល់ពេល! អត់នេះទៅ។ ដល់ពេលព្រឹកឡើងបាត់គេថាអស់ហើយ។

កៈ ចាស!

ខៈ បាត់អស់ហើយបានដើរទៅកាធីកូនបងជីនេះណាស់?

កៈ ចាស!

ខៈ គាត់មកសួរខ្ញុំថាៈ មីងមាគាត់ថាមកមានបានមកផ្ទះទេ! បែបគេយកទៅបាត់ហើយ។ ហើយឪពុករបស់ខ្ញុំក៏បាត់ដែល។ ហើយដល់ពេលរួចទៅក៏ទៅជាមួយគ្នានឹងទៅ។

កៈ ចាស!

ខ៖ ចាស! យប់នឹងច្រើន។ ហើយបាត់នឹងក៏បាត់រហូតទៅ។

ក៖ ចាស!

ខ៖ ចាស! យើងបាត់គិតទៅមិនបាននែ...? មិនទាន់បានកន្លះខែផងទាន់ក៏នាំគ្នារត់មកផ្ទះវិញហាស់។

ក៖ ចាស!

ខ៖ ជំនាន់ដែលគេចូលមកកុងកាំងនឹងឯង។

ក៖ ចាសចាស!

ខ៖ នឹងហើយ! ក៏នាំគ្នារត់មកផ្ទះវិញ។

ក៖ ចាស!

ខ៖ ដល់ពេលមកដល់,មកដល់ស្រុកភូមិននេះមិនទាន់មានផ្ទះឯណា។

ក៖ ចាសចាស!

ខ៖ ហើលយចេះតែដើរនៅផ្ទះប្រជាជនដែលគេធ្វើតូចៗនៅហើយគេរត់បាត់ទៅហើយដែល។

ក៖ ចាស!

ខ៖ ស្រាប់តែឮគ្រាប់ស្មើនឹងឯងឮគ្រប់មកពីឈ្លាំងមកវាចូលមកហាស់?

ក៖ ចាសចាស!

ខ៖ នាំគ្នាវិចប្រវេចវិចអីរត់ទៀតហើយ!ហើយនាំគ្នាដើរកាត់តាមនឹងហើយទៅពេទ្យយាយាជីហោក។

ក៖ ចាស!

ខ៖ ហើយទៅស្នាក់នៅនឹងឯង! នៅនឹងពេទ្យតយាយជីនឹងឯង។

ក៖ ចាសអុំ!

ខ៖ បានមានស្រូវមានអីហើយបុកអង្ករបុកអីនៅនឹង។

ក៖ អូ!

ខ៖ បាយទឹកអីគឺនៅណឹង។ ហើយចេះតែឮស្វរក្តុងៗៗ។ រីលៗពីនឹងទៅដែលហាស់?

ក៖ ចាសអ៊ំ!

ខ៖ វាឆាប! យន្តហោះចុះតែទំលាក់គ្រាប់ ហើយរោយអស់ហើយនៅតាមម្តុំអ៊ុំបោះយិនអីនឹង។

ក៖ ចាសអ៊ំ!

ខ៖ ហើយផ្ទះអីឆះអស់ហើយនៅម្តុំខាងនឹងហ្ន។

ក៖ ចាស!

ខ៖ ចុះកាបាល់ហោះវារោយគ្រាប់ទំលាក់ឆះអស់។

ក៖ ចាស!

ខ៖ ប៉ុន្តែមនុស្សរត់អស់ហើយគ្មានបានទៅនេះអីទេ។

ក៖ ចាស។

ខ៖ ចាស! ហើយះអ្នកណាមិនរត់។ ហ្វ...នឹកឃើញកាលនឹងខ្ញុំភ័យណាស់។យប់ឡើងដែល យើងមិនទាន់បានចេញទៅហាស់អ៊ុំរើយផងអីផងសុទ្ធតែអ្នកកូនបៅហាស់។

ក៖ ចាស!

ខ៖ រត់ចូលនៅក្នុងប្រឡាយហ្ន។

ក៖ ចាសអ៊ំ!

ខ៖ រត់ចូលនៅក្នុងប្រឡាយនឹងឯង! ហើយដេកនៅនឹងក្នុងប្រឡាយនឹងឯង។

ក៖ ចាសអ៊ំ!

ខ៖ អត់ហ៊ាននៅផ្ទះទេ។ចុះបើថាមកសិទ្ធតែឆ្លងមកតាមថ្នល់រទេះភ្លើងហើយកាត់មកតាមណឹង ហាស់។

ក៖ ចាសអ៊ុំ!

ខ៖ កាត់មកឮមាត់ដែលតើ!មានម្តងនឹងកាត់មកនិយាយថាពីភ័យអើយភ័យ!វាងតាមប្រឡាយ នឹងឃើញថា បើវាចូលមកតាមប្រឡាយនឹង!ហើយដាក់តែមួយគ្រាប់មកនៅក្នុងប្រឡាំយយើង ចំហើយកន្លែងនឹងហ្ន៎!

ក៖ ចាសអ៊ុំ!

ខ៖ ចុះបើនាំគ្នាពួន...ហើយចុះគ្នាកូនក្មេងគ្នាមានទៅដឹងអីអាណាវាឈ្លានបៅវាយំ។ ហើយ ភ័យនឹងអាកូនវាយំនឹងទៀត។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! ហើយចេះតែថាទៅ៖ កុំយំៗ! ហើយចុះគ្នាមានទីដឹងអី ប្អូនប្រាំខែហ្ន៎។

ក៖ ចាស!

ខ៖ ឈ្លានបៅដឹងតែវាយំហើយ។

ក៖ ចាស!

ខ៖ ហើយឥឡូវនេះវាធំអស់ហើយ។ កូនអ៊ុំរើយធ្វើការហើយមានចៅមានអីអស់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! គិតទៅ ដំណាលក្មួយខ្ញុំមួយនេះឯង។ ប្អូនគ្នាពីរបីឆ្នាំបានពីខែ ហើយយាយខូច ចោល។

ក៖ ចាសអ៊ុំ!

ខ៖ វេទនាមែន។ កំសត់ណាស់ចា។

ក៖ ចាសអ៊ុំ! អញ្ចឹងសម័យនឹងអ៊ុំមានប្តីមុនពេលដែលប៉ុលពតចូលមែនទេ?

ខ៖ ចាស! មានប្តីមុនតាំងពីមុនសង្គមមកម្ល៉ះ។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានកូនចៅប៉ុន្មាននាក់ដែលតាំងពីនឹងរហូតមកដល់ឥឡូវ? កូនចៅហាស់? កូនចង្កើតរបស់អ៊ុំហាស់?

ខ៖ កូនបង្កើតរបស់ខ្ញុំហូ?

ក៖ ចាសអ៊ុំ!

ខ៖ អត់មានទេ! ទៅណឹងទៅមាននៅនឹងសម័យប៉ុលពតមួយតែប៉ុនណឹង។ អត់មានទេ! នៅនឹងវត្តមួយនឹង។ ទៅបង្កើយនៅកបិននឹងឯង។ ស្លាក់ថ្នាំបងរបស់វាស្លាក់ថ្នាំមួយ។

ក៖ អូ្ហ!

ខ៖ ទៅឯនឹងកូនងាលង់ទឹកមួយ, ដែលបីពីនេះទៅ។

ក៖ អូ្ហចាស!

ខ៖ ហា! នឹងហើយ។ ហើយទៅកើតនៅកន្លែងនឹងមួយ។ ហើយទៅកើតនៅកន្លែងនឹងមួយវាខូ

ជាមួយគ្នានឹងយាយហូ!? កាលនឹង។

ក៖ អញ្ចឹង?

ខ៖ ចាស! ក្តារឈ្លួសជាមួយនឹងយាយនឹងឯង។

ក៖ ចាស!

ខ៖ ដុតចៅមួយ ហើយយាយមួយ។

ក៖ ហុឹម!

ខ៖ ហើយខ្ញុំនេះម៉ែអាវត្តដឹកទៅពេទ្យ។ ឈើខ្លាំងមែនទែនហាស់។

ក៖ ចាស!

ខ៖ បានគេដឹកទៅពេទ្យ។ ហើយយកបាយទៅអី ខ្ញុំលេបមិនរួចទេដឹងតែពីយំហូ។

កៈ ចាស!

ខៈហើយបាយនឹងអោយទៅគេហូបទៅ។ហើយប្រាប់តែតាមត្រង់ទៅថាបុណ្យខ្មោចម្តាយរបស់ខ្ញុំ

មានបាននៅឯងណាកាលណឹងមានតែបងប្អូនទេដែលពួកគាត់ជាអ្នកនៅធ្វើបុណ្យអោយហូកាលណឹង។

កៈ អូចាសអ៊ុំ!

ខៈ ចាស! ដល់តែរួចបុណ្យចប់បុណ្យមកទៅនៅបានកន្លះខែបានរៀងគ្រាន់មកនឹង។

កៈ ចាស!

ខៈ រួចបុណ្យរួចអីអស់ហើយចប់។ ដល់ពេលមកកើតវាទៀតនេះមកវេទនាទៀត។

កៈ ចាសចាស!

ខៈ ចាសចាស! ហើយប្រវត្តិរបស់ខ្ញុំមានច្រើនណាស់។

កៈ ចាសចាស! អញ្ចឹងតើអ៊ុំមានអ្វីទៀតដែលឡរអត់?

ខៈ អ្វីដែល?

កៈ ដូចថាតើអ៊ុំមានអ្វីទៀតដែឡឬអត់ទេ?

ខៈ អូ! មាននិយាយចប់អស់ហើយសម័យនឹង។ ពីនឹងមកបានតែមកពីផ្ទះទៀត។ មកផ្ទះនឹងរវល់តែនឹងរត់ចុះឡើងចុះឡើង។ មិនមានទាន់បានធ្វើផ្ទះនៅអី។ អាន័យតែទៅឯនេះទៅឯនោះ។

កៈ ចាស!

ខៈ នែ! ដាំបាយអីទៅមិនហ៊ានដើរទៅណាអីទេ។ នៅតែជុំគ្នាអញ្ចឹងទៅ។

កៈ ចាស!

ខ៖ ហើយអោយតែឮសូរគ្រាប់អីភ្លាមនាំគ្នារត់ចុះចូលប្រឡាយ។

ក៖ ចាស!

ខ៖ ឮសូរគ្រាប់រត់ចុះចូលប្រឡាយ។

ក៖ ចាសអ៊ុំ!

ខ៖ អញ្ចឹងឯង។

ក៖នឹងបើប្រៀបធៀបពីជីវិតរបស់អ៊ុំពីមុនមកសព្វថ្ងៃនេះហាស់តើខុសគ្នាយ៉ាងម៉េចដែលច្រើន

ដែលឬអត់?

ខ៖ ខុសគ្នាច្រើន។ ទោះបីជាំយើងមិនមានបានតែពីតមែនប៉ុន្តែយើងចង់បានអៅយើងបាន។

ក៖ ចាសចាស!

ខ៖ចាស!ហើយមានប្រាក់តិចតួចអីទៅទិញទៅ។ចង់បានរបស់អីយើងបានហើយកាលណោះ យើងវាគ្មានសោះម៉ងហាស់។ចាសហើយគ្មានបានស្អីទេ។ចង់អីក៏មាន។ហើយធ្វើអីដាំដុះអីទៅ ដូចថាវាមានកម្លាំងជាំងពីដើមហាស់។

ក៖ ចាសចាស!

ខ៖ ពីដើម! វាទាល់ច្រកដូចថាចេញវាមិនរួច, ធ្វើការអីក៏វាមិនកើត។ សង្គ្រាមចាស

ក៖ ចាសអ៊ុំ!

ខ៖ ចាស! មិនដឹងថាទៅណាហើយមកណា។ គេឃាមគ្រប់កន្លែងមិនអោយចេញ។

ក៖ ចាស!

ខ៖ ឥឡូវនេះអត់ទេ! ចង់ទៅណាបានតាមចិត្តយប់ថ្ងៃអី។ យើងមិនពិបាកដូចពីដើម។

ក៖ ចាសអ៊ុំ!

ខ៖ និយាយទៅវាសប្បាយជាង។

ក៖ ចាស!

ខ៖ ចាស!

ក៖អញ្ចឹងពីមុនពិបាកមែន!ប៉ុន្តែតើអ៊ុំមានអ្វីមួយដែលអ៊ុំចូលចិត្តដែរឬទេ?ដូចថាពិបាកមែនតែមានអ្វីមួយដែលថាអោយអ៊ុំចូលចិត្តហើយស្រឡាញ់ដែលឬទេ?

ខ៖ ដូចជាមិនយល់។ ហាហា!

ក៖ ហាហា! ដូចថាកាលដែលអ៊ុំនៅពីក្មេង រហូតដល់អ៊ុំមកដល់ពេលឥឡូវនេះហាស់?

ខ៖ ចាសអ៊ុំ!

ក៖ តើអ៊ុំមានអ្វីដែរអ៊ុំចូលចិត្តហើយស្រឡាញ់ដែលឬអត់ពីជីវិតរបស់អ៊ុំដែលកាលនៅពីក្មេងហាស់?

ខ៖ មិនយល់ដូចមិនដឹងឆ្លើយ។

ក៖ អត់ដឹងទេន៍អ៊ុំ?

ខ៖ ចាសអត់ដឹង។

ក៖ អូខេ! ឥឡូវដូចថាជីវិតរបស់អ៊ុំពេលឥឡូវនេះសម័យនេះតើអ៊ុំសប្បាយចិត្តនឹងរីករាយជាមួយអីគេ ជាមួយនឹងជីវិតរបស់អ៊ុំដែលឬអត់? ជាមួយអ្វីគេខ្លះហើយមានអីគេខ្លះចឹងហាស់?។

ខ៖ អូ! មិនមានអី។ អោយតែបានរស់នៅជួបជុំជាមួយកូនចៅមួយនឹងអ៊ុំបានសប្បាយហើយ។

ហើយកុំអោយតែនៅតែឯងកំម៉ោង១។

ក៖ ចាស!

ខ៖ចាស!ហើយនៅតែនឹកឃើញអ្នកដែលគេយកទៅសម្លាប់ទៅអីនឹងនៅតែនឹកឃើញចឹងឯង។

ក៖ ចាសអ៊ុំ! អញ្ចឹងឥឡូវអ៊ុំសប្បាយចិត្តបានជួបជុំគ្រុមគ្រួសារហើយនឹងកូនចៅឥឡូវ?

ខ៖ ចាសនឹងហើយ។

ក៖ ចាស!

ខ៖ យើងមានក្រអីអោយតែយើងបាននៅជុំគ្នាទៅណាស់!?

ក៖ ចាសអ៊ុំ!

ខ៖ ហើយបើយើងព្រាត់ប្រាស់គ្នាយ៉ាប់យើងពិបាក។

ក៖ចាសអ៊ុំ!អញ្ចឹងកាលដែលអ៊ុំនៅពីក្មេងហាស់?តើជីវភាពរបស់គ្រួសារគ្រួសាររបស់អ៊ុំតើយ៉ាងម៉េចដែល?

ខ៖ គ្រាន់តែថា.. មួយនឹងយើងវាមិនរកគេមិនជំពាក់គេ។ នឹងបានមួយគ្រប់មាត់។

ក៖ ចាសអ៊ុំ!

ខ៖វាមិនពិបាកដើរហែមរហាមហើយមិនពិបាកដើររកអ្នកណា។ព្រលឹមឡើងដឹងតែធ្វើដស្រែចំការរបស់យើងហាស់?

ក៖ ចាសអ៊ុំ!

ខ៖ ចាស! ហើយចង់ដាំអីក៏ធ្វើទៅ វាមានតែប៉ុនណឹងឯង។

ក៖ ចាសអ៊ុំ! ចាសអញ្ចឹងជីវិតរបស់អ៊ុំនៅពេលនឹងតើអ៊ុំមានអាហារហូបចុកអីគ្រប់គ្រាន់ដែលឬ

ទេ?

ខ៖ មាន! មានហូបចុកអីគ្រប់គ្រាន់។

ក៖ ចាសគ្រប់គ្រាន់ហីអ៊ុំ!?

ខ៖ ចាសគ្រប់គ្រាន់! ហើយកាលពីសង្គមមានគ្រប់គ្រាន់ហើយសប្បាយជាងសព្វថ្ងៃនេះទៀត។

ក៖ អូ! អញ្ចឹងវិញ?

ខ៖ ចាសនឹងហើយ! សប្បាយជាំងសព្វថ្ងៃនេះ។

កៈ ចាស!

ខៈចាស!ស្រូវពេញៗជង្រុកហាស់!?ទាល់តែគាត់ធ្វើកើតបានគាត់លក់។ហើយគាត់ធ្វើចំការដាំដុះ ចាយមិនអស់។ ចាស! នឹងពីសម័យសង្គម។

កៈ ចាសពីសង្គមមក។

ខៈ ចាសនឹងហើយ! ដល់ពេលពីចប់ប៉ុលពតទៅនឹង។និយាយថាពីផ្លែម្នាស់ក្រូចអីពេញចំការ។

កៈ ចាសអុំ!

ខៈ ប៉ុលពតវាទុកអោយយើងធ្វើពូជ។

កៈ អូ! ហាហា!

ខៈ វាមិនកាត់មិនចិតអីទេវាទុកធ្វើពូជ ហើយទុកយូរៗទៅវារឡះអស់ហើយមានអី។

កៈ ចាសចាស!

ខៈ វាមិនដឹងថាយើងដាំដើមអី, វាទុកគ្រាប់អោយយើងធ្វើពូជ។

កៈ អូ! ចាសហាហា!

ខៈ នឹងហើយ! ម្នាស់។

កៈ ប៉ុលពតអត់ឆ្លាតទៃកាលនឹង។

ខៈ មានដែលប៉ុន្តែគ្រាប់វាតូចៗ។ ហើយមានទៅដាំដុះអី។ គេដាំតែដើមទេ។

កៈ ចាស! ប៉ុលពតកាលនឹងអត់ឆ្លាតហាស់! ហាហា!

ខៈ នឹងហើយ!

កៈ យកគ្រាប់ម្នាស់យកទៅដាំ។

ខៈ ហាហា! អត់ឆ្លាតទេ។ ឆ្លាតអីអស់ផ្ទះសំបែងម៉ូតូអីនៅជាប់ឆ្អឹងទទេ។

កៈ ចាសអ៊ុំ! អញ្ចឹងពីមុនអ៊ុំមានអាហារហូបចុកគ្រាប់គ្រាន់ហើយអ៊ុំចង់បានអីអ៊ុំមាននឹងញាំ!

ខៈ ចាសចាស!  នឹងហើយប៉ុន្តែវាមិនសូវសប្បាយដូចពីសម័យសង្គម។

កៈ ចាស!

ខៈ ពីសម័យសង្គមនឹកឃើញទៅសប្បាយណាស់។ បងនោះអីក៏គាត់នៅភ្នំពេញដែលតើ។

កៈ អូ!

ខៈ នឹងហាស់ដែលខ្ញុំទៅនៅផ្ទះរបស់គាត់នៅវត្តសំពៅ, បងនឹងតើ។

កៈចាស!អញ្ចឹងនៅក្នុងគ្រុមគ្រួសាររបស់អ៊ុំហាស់?តើមានអ្នកណាដែលគាត់ចេះជំនាញអ្វីមួយទេដែលថាជាខ្មែររបស់យើងហាស់? ដូចជាចេះធ្វើកន្រ្តកឬក៏ធ្វើអីតើមានដែលឬទេអ៊ុំ? ដូចជា

ត្បាញអីចឹងហាស់?

ខៈ អត់មានទេ! អត់ទេអត់ចេះទេ។

កៈ អត់មានទេន៍អ៊ុំ?

ខៈ ចាស! មានតែខាងធ្វើស្រែចំការនឹង។ ហើយអត់ចេះទេត្បាញអីនឹងហូ។

កៈ ចាសអ៊ុំ! អញ្ចឹងនៅក្នុងគ្រុមគ្រួសាររបស់អ៊ុំ ជីដូនជីតារបស់អ៊ុំពួកគាត់ជាអ្នកធ្វើស្រែចំការ?

ខៈ ចាស! ធ្វើស្រែចំការ។

កៈ ចាស! គាត់មានស្រែច្រើនហីអ៊ុំ?

ខៈ ចាសមានច្រើន! ហើយគាត់ចែកកូនចៅអស់។

កៈ ចាស! ចុះតើឥឡូវនេះតើអ៊ុំមានស្រែធញរើទៀតទេ?

ខៈ សព្វថ្ងៃនេះអត់មានទេ។ អត់មានទេ។

កៈ ចាសអ៊ុំ!

ខ៖ ដីដែលគេយកអោយបានតែមួយចំណែកប្តីខ្លួនឯង។ ហើយស្រែដែលជួយគេនឹងគេយកអស់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយ! គេយកគេចូលមកគេយកអស់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ នៅតែគេចែកអោយប៉ុន្មានម្នាក់នោះ។ ដែលគេចែកអោយគ្នាម្នាក់ប៉ុន្មានហិតតាម្នាក់នឹង។ មួយនឹងនៅ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយសព្វថ្ងៃនេះបានតែឈ្នួលនឹង។

ក៖ ហាហា!

ខ៖ នឹងហើយតិច។

ក៖ចាសអ៊ុំ!អញ្ចឹងតាំងពីអ៊ុំធំដឹងក្តីរហូតមកដល់ប៉ុននេះតើអ៊ុំមានបទពិសោធធ្វើការងារអ្វីខ្លះ ដែលក្រៅពីធ្វើស្រែចំការហាស់?

ខ៖ ខ្ញុំអត់ទេ! អត់មានបានទៅណាទេ, នៅតែផ្ទះហើយធ្វើតែស្រែចាំករនឹងឯង។

ក៖ ចាសអ៊ុំ! អញ្ចឹងនៅក្នុងមួយជីវិតរបស់អ៊ុំ, អ៊ុំធ្វើតែស្រែចំការមួយមុនទែន៍អ៊ុំ?

ខ៖ ចាសចាសនឹងហើយ។ ជាមួយម៉ែហើយឪនឹង។

ក៖ ចាស!

ខ៖ ចាស! ហើយអស់ពីស្រែទៅ, ភ្ជួរដីដាំសណ្តែកបាយអីចឹងទៅ។

ក៖ ចាស!

ខ៖ ចាស!ហើយដល់ពេលរួចទៅដល់ខែធ្វើស្រែទៀត។

កៈ ចាស! វិលទៅវិលមក។

ខៈ ចាសនឹងហើយវិលទៅវិលមក។

កៈ ចាសនឹងហើយអុំ! អញ្ចឹងតើអុំអាចប្រាប់ខ្ញុំបានទេថាតើពេលវេលាមួយណាដែលអុំគិតថា

ពិបាកជាងគេនៅក្នុងជីវិតរបស់អុំហាស់?

ខៈ ដែលពិបាកនោះ?

កៈ ចាសអុំ!

ខៈ ពីសម័យប៉ុលពតនឹងឯងដែលពិបាកហ្វ! ពិបាកនឹងអត់វាពិបាកសព្វគ្រប់នឹងឯង។

កៈ ចាស!

ខៈ ចាស! ហើយប្ដីគេយកទៅសម្លាប់ហើយព្រលឹមឡើងទៅចោលកូនចៅ។ ពិបាកទាំងអស់។

កៈ ចាស!

ខៈ ហើយដល់ពេលព្រលឹមឡើងគេមកយកកូនទៅហើយ។

កៈ ចាសអុំ!

ខៈ ហើយមកដល់វិញទៅយកកូនពីគេមកវិញ។

កៈ ចាស!

ខៈ គេមើល។

កៈ ចាសអុំ!

ខៈ ម្ដាយទៅឆ្ងាយ។ បងដូចបងនោះបានគាត់ដើរឆ្ងាយ។

កៈ ចាសអុំ! ហើយអញ្ចឹងតើអុំបានឆ្លងកាត់នៅការលំបាករបស់អុំនឹងតើបានដោយរបៀបណា

?ដូចថាពេលនឹងខ្ញុំដឹងថាពិបាកមែនតើអ៊ុំបានធ្វើយ៉ាងម៉េចដើម្បីជំនេះនៅការពិបាករបស់អ៊ុំបាននៅពេលនឹងហាស់?

ខ៖ ហ៊ឹម!មិនដឹងថាជំនេះយ៉ាងម៉េចព្រោះដូចថាកំពុងតែនៅក្នុងកណ្ដាប់ដៃរបស់គែហើយគេ

ប្រើយើង! ហើយយើងមានទៅធ្វើអីកើតអត់ទាំងអស់។

ក៖ ចាស! អញ្ចឹងយើងធ្វើតាមគេ?

ខ៖ នឹងហើយ! គែអោយទៅណាយើងទៅធ្វើតាមគេ។ ហើយគេអោយធ្វើអីយើងធ្វើនឹង។

ក៖ ចាសអ៊ុំ!

ខ៖ មិនទៅណារួចទេ។

ក៖ ចាសអ៊ុំ! អញ្ចឹងតើបេលវេលាមួយណាដែលគិតថាសប្បាយជាងគេនៅក្នុងជីវិតរបស់អ៊ុំ?

ពេលដែលអ៊ុំមានគ្រួសារពេលដែលអ៊ុំមានកូនចៅឬក៏ពេលណាដែលអ៊ុំគិតថាសប្បាយចិត្តជាងគេនៅក្នុងជីវិតរបស់អ៊ុំ?

ខ៖ អូ! មួយនឹងមានតែនៅជុំគ្នានឹងហើយ។ ជួបជុំគ្រុមគ្រួសារដែលគែមិនទាន់យកប្ដីយកអីយើ

ងនៅ, នៅផ្ទះនីឡើយហាស់។?

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយនៅពីសង្គមនឹងហើយដែលសប្បាយហូ!

ក៖ ចាសអ៊ុំ!

ខ៖ ដែលសប្បាយជាំងតែបង្ហាស់ហូ។

ក៖ ចាស!

ខ៖ កូនចីមួយពីអីនៅជុំគ្នា, ហើយទៅណាទៅទាំងអស់គ្នា។

ក៖ ចាសនឹងហើយអ៊ុំ! អ៊ុំនិយាយាថាសប្បាយជាងសម័យឥឡូវនេះឆ្ងាយ។ហាសហា

ខ៖ ចាសនឹងហើយសប្បាយជាងសម័យឥឡូវនេះឆ្ងាយណាស់។

ក៖ ចាសនឹងហើយ!

ខ៖ ហើយសព្វថ្ងៃនេះមានស្អី! អស់អីរលីងមានតែដីទទេនឹងចាស! ហើយគ្មានស្អីលក់ទេ។

ក៖ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំសង្ឃឹមថាចង់បានអ្វីទៅថ្ងៃខាងមុខទៀត? ដូចថាតើអ៊ុំសង្ឃឹមថាចង់បានអ្វី?

ខ៖ ចង់បានតែចង់បើចង់វាមិនមានមិនដឹងថាទៅធ្វើអ្វីកើតអីបាន! ហើយចិត្តនោះវាចង់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ វាចង់មានចង់បាននោះ។ ប៉ុន្តែមិនដឹងថាទៅធ្វើស្អីអោយវាមានបាននោះ។ បើយើងសព្វថ្ងៃនេះវាចាស់ទៅហើយ! ហើយយើងទៅធ្វើស្អីបានទៅរកស្អីបាន។ រស់ដោយសារតែគេចិញ្ចឹមហ្វបើកូនចៅរកចិញ្ចឹមនៅផ្ទះ។

ក៖ ចាសនឹងហើយអ៊ុំ!

ខ៖ នឹងហើយ!

ក៖ ចាស! អញ្ចឹងចង់អោយកូនចៅពួកគាត់មានបានន៍អ៊ុំ?

ខ៖ ចាសនឹងហើយ! ចង់អោយកូនចៅគេមានបាន។ ហើយមានទៅសង្ឃឹមអ្វីទៀត។

ក៖ ហើយបានលុយចិញ្ចឹមអ៊ុំដែល។

ខ៖ ចាសអញ្ចឹង។

ក៖ ហាហា!

ខ៖ ចាសគេចិញ្ចឹម។

ក៖ ចាសអ៊ុំ!

ខ៖ កុំតែមានកូនចៅកុំអីទៅធ្វើអ្វីបាននឹងហ្វ!?

ក៖ ចាសអ៊ុំ!

ខ៖ ហើយនៅតែផ្ទះអញ្ជឹង។

ក៖ ចាសចាស! នឹងហើយអ៊ុំ។ អញ្ជឹងខ្ញុំគិតថាខ្ញុំក៏អស់អ្វីសួរអ៊ុំដែលហើយ។

ខ៖ អើៗ។

ក៖ ចាស! អញ្ជឹងខ្ញុំសូមអរគុណអ៊ុំច្រើនដែលបានចំណាយពេលវេលាដ៏មានតម្លៃអោយខ្ញុំធ្វើការសម្ភាសអ៊ុំនៅថ្ងៃនេះ។

ខ៖ អើនឹងហើយ។

ក៖ ចាសអ៊ុំ! អញ្ជឹងតើខ្ញុំសូមថតរូបអ៊ុំមួយតើបានដែលឬទេ?

ខ៖ ចាសថតទៅមានស្អីសក់ឡើងយ៉ាប់។

ក៖ ហាហា! អរគុណច្រើនអ៊ុំ។

ខ៖ ចាស៕